# ព្រះរាជក្រឹត្យ

នស/រកត/០៩០៨/១០៥៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខនស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើ ច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់សេចក្តីសម្រេចលេខ ៦០៤/០៨ គជប សសរ ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការប្រកាស លទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី ៤ ថ្ងៃ អាទិត្យ ទី ២៧ ខែ កក្កដា ឆ្នាំ ២០០៨
- បានទ្រង់យល់សំណើរបស់គណបក្សប្រជាជនកម្ពុជាលេខ ៦៤៤ លគគក ចុះថ្ងៃទី ២៤ខែ កញ្ញា ឆ្នាំ ២០០៨
- បានទ្រង់យល់សំណើរបស់ព្រឹទ្ធសមាជិករដ្ឋសភានីតិកាលទី៤ លេខ ៧៧៣ រស ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០០៨

## ត្រាស់បង្គាប់

**មាត្រា ១.-** ត្រូវបានចាត់តាំង សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ជា នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានភារកិច្ចរៀបចំសមាសភាពរាជរដ្ឋាភិបាលកម្ពុជា ដើម្បីសុំសេចក្តីអនុម័តទុកចិត្តពីរដ្ឋសភា ។

**មាត្រា ៣.-** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

លេខៈ ៩៩៤ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០០៨
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ពរល-០៩០៩-១០៧៣

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០០៨

ឃឹន ជិនកេន